# សាសនាចក្រតែមួយដែលពិត ហើយសកម្ម

អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀន ៖



ព្រះអម្ចាស់បានប្រកាសថា សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយគឺជា « សាសនាចក្រតែមួយ ដែលពិត ហើយសកម្មនៅលើផ្ទៃផែនដីទាំងមូល » ( គ.&ស. ១:៣០ ) ។ សាសនាចក្រដែលបានស្តារឡើងវិញនេះគឺពិត ដោយសារវាជាសាសនាចក្ររបស់ព្រះអង្គសង្គ្រោះ ហើយទ្រង់គឺជា « ផ្លូវជាសេចក្តីពិត ហើយជាជីវិត » ( យ៉ូហាន ១៤:៦ ) ។ ហើយវាជាសាសនាចក្រដែលសកម្ម ដោយសារតែកិច្ចការ និងអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។ ( ដេវីឌ អេ បែដណា « Receive the Holy Ghost » Liahona ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ៩៧ )

ប្រធាន ដាល្លិន អេក អូក ក្នុងគណៈប្រធានទីមួយបានបង្រៀន ៖



លក្ខណៈពិសេសចំនួនបី—(១) ភាពពោរពេញនៃគោលលទ្ធិ (២) អំណាចបព្វជិតភាព និង (៣) ទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ—ពន្យល់អំពីមូលហេតុដែលព្រះបានប្រកាស . . . ថានេះគឺជាសាសនាចក្រតែមួយគត់ដែលពិត ហើយសកម្មនៅលើផ្ទៃផែនដីទាំងមូល ។ . . .

ដំណឹងល្អដែលបានស្តារឡើងវិញនៃព្រះយេស៊ូវគ្រីស្ទ គឺមានលក្ខណៈទូលំទូលាយ ជាសកល ពេញដោយសេចក្តីមេត្តាករុណា និងពិត ។ . . .

ដោយមានអំណាចបព្វជិតភាព ថ្នាក់ដឹកនាំ និងសមាជិកដែលមានសិទ្ធិអំណាចត្រឹមត្រូវនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ មានអំណាចដើម្បីធ្វើពិធីបរិសុទ្ធបព្វជិតភាពដែលតម្រូវឲ្យមាន ដូចជាពិធីបុណ្យជ្រមុជទឹក អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ និងការរៀបចំពិធីសាក្រាម៉ង់ជាដើម ។

កូនសោនៃបព្វជិតភាព ដែលព្យាការីជាទីស្រឡាញ់នៃយើងកាន់ . . . និងព្យាការី និងប្រធានសាសនាចក្រគ្រប់រូបកាន់ ផ្តល់សិទ្ធិឲ្យលោកទទួលបានវិវរណៈជំនួសឲ្យសាសនាចក្រទាំងមូល ។ សាសនាចក្រនេះ « សកម្ម » ដោយសារយើងមានព្យាការីដែលបន្តផ្តល់ព្រះបន្ទូលនៃព្រះអម្ចាស់ដល់យើង ដែលចាំបាច់សម្រាប់ជំនាន់របស់យើង ។

មូលហេតុទីបីនៃការដែលយើងគឺជាសាសនាចក្រដ៏ពិតតែមួយនោះគឺថា យើងមានសេចក្តីពិតដែលបានបើកសម្តែងអំពីលក្ខណៈនៃព្រះ និងទំនាក់ទំនងរបស់យើងជាមួយទ្រង់ ហេតុដូច្នេះហើយយើងមានទីបន្ទាល់ដ៏ពិសេសអំពីព្រះយេស៊ូវគ្រីស្ទ ។ ( ដាល្លិន អេក អូក « The Only True and Living Church » New Era ខែ សីហា ឆ្នាំ ២០១១ ទំព័រ ៣–៥ )

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2024 by Intellectual Reserve, Inc. All rights reserved. PD80007812_258_022-1